## នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
## នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 13-Aug-2013, 09:18
CMS/CFO: Phok Chanthan

<u>ព័ត៌មានពិស្តារអំពីការដាក់ឯកសារ</u>

សំណុំរឿងលេខ៖ ០០២/១៩-០៩-២០០៧-អវតក/អជសដ

ភាគីដាក់ឯកសារ៖ លោក **ខៀវ សំផន**

ដាក់ជូន៖ អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម៖ **បារាំង**

កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០១៣

<u>ចំណាត់ថ្នាក់ឯកសារ</u>

ចំណាត់ថ្នាក់ឯកសារស្នើឡើងដោយភាគីដាក់ឯកសារ៖ **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះសាលាដំបូង៖ **សាធារណៈ/Public**

ប្រភេទនៃចំណាត់ថ្នាក់៖

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្តោះអាសន្ន៖

ឈ្មោះមន្ត្រីទទួលបន្ទុកផ្នែកសំណុំរឿង និងឯកសារ៖

ហត្ថលេខា៖

---

# សំណើសាជាថ្មីរបស់មេធាវីការពារក្តីលោក ខៀវ សំផន សុំលើកពេល ចាប់ផ្តើមគិតកាលកំណត់ដាក់សារណាបញ្ចប់ការពិភាក្សាដេញដោល

---

<u>ដាក់ដោយ</u>៖

**មេធាវីការពារក្តីលោក ខៀវ សំផន**

មេធាវី គង់ សំអុន

មេធាវី Anta GUISSÉ

មេធាវី Arthur VERCKEN

មេធាវី Jacques VERGÈS

<u>ដាក់ជូន</u>៖

**អង្គជំនុំជម្រះសាលាដំបូង៖**

ចៅក្រម និល ណុន

ចៅក្រម Silvia CARTWRIGHT

ចៅក្រម យូរ ឧត្តរា

ចៅក្រម Jean-Marc LAVERGNE

ចៅក្រម យ៉ា សុខន

**ជំនួយការ៖**

លោកស្រី សេង សុជាតា

កញ្ញា Marie CAPOTORTO

កញ្ញា Mathilde CHIFFERT

កញ្ញា Vera MANUELLO

កញ្ញា Soumeya MEDJEBEUR

កញ្ញា អ៊ុច ស្រីផាត់

លោកស្រី សុគន្ធ មោនីកា

កញ្ញា Blandine ZELLER

**សហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក Andrew CAYLEY

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់**

**ក្រុមមេធាវីការពារក្តីទាំងអស់**

# គោរពជូនអង្គជំនុំជម្រះសាលាដំបូង

១. នៅថ្ងៃទី ២៣ និងថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០១៣ អង្គជំនុំជម្រះសាលាដំបូង ("អង្គជំនុំជម្រះ") បានប្រកាសបិទសវនាការលើអង្គសេចក្តី និងបានកំណត់រយៈពេលដាក់សារណា និងធ្វើសេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល ដោយខ្វល់ពីការព្រួយបារម្ភចំពោះការត្រៀមរៀបចំ ដែលមេធាវីការពារក្តីធ្លាប់បានលើកឡើងជាច្រើនលើកច្រើនសារួចមកហើយ[1]។

២. នៅថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០១៣ មេធាវីការពារក្តីលោក ខៀវ សំផន បានស្នើឲ្យអង្គជំនុំជម្រះតុលាការកំពូលបញ្ឈប់កិច្ចដំណើរការនីតិវិធី ដោយសារតែអង្គជំនុំជម្រះសាលាដំបូងបានរំលោភយ៉ាងធ្ងន់ធ្ងរទៅលើសិទ្ធិរបស់មេធាវីការពារក្តីក្នុងការទទួលបានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់សម្រាប់រៀបចំការពារខ្លួន[2]។

៣. នៅថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ២០១៣ មេធាវីការពារក្តីលោក នួន ជា បានស្នើសុំតាមរយៈអ៊ីមែលឲ្យគិតពេលវេលាសម្រាប់រៀបចំសារណាបញ្ចប់ការពិភាក្សាដេញដោល ចាប់ពីពេលដែលសេចក្តីសម្រេចមានសំអាងហេតុលើភាពអាចទទួលយកបាននៃកំណត់ហេតុស្តាប់ចម្លើយរាប់ពាន់ ត្រូវបានផ្តល់ជូនភាគី ជាបីភាសាផ្លូវការរបស់ អ.វ.ត.ក។

៤. នៅថ្ងៃដដែលនោះ មេធាវីការពារក្តីលោក ខៀវ សំផន បានគាំទ្រសំណើនេះ ដែលខ្លួនធ្លាប់បានធ្វើឡើងជាច្រើនលើកច្រើនសាមកហើយ ក្នុងចំណោមសំណើផ្សេងៗទៀត។

៥. នៅថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០១៣ មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះ បានប្រាប់មេធាវីការពារក្តីទាំងពីរក្រុម ឲ្យលើកបញ្ហានេះ តាមរយៈសំណើជាផ្លូវការ *"ដោយពិចារណាទៅលើសារៈសំខាន់*

---

[1] ប្រតិចារឹកសវនាការ ថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០១៣ ឯកសារ E1/227.1 ទំព័រ ៥៥-៥៧, ការបញ្ជាក់ពីកាលបរិច្ឆេទនៃការដាក់សារណា និងសេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល ថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០១៣ ឯកសារ E295។

[2] សំណើបន្ទាន់របស់មេធាវីការពារក្តីលោក ខៀវ សំផន សុំឲ្យបញ្ឈប់កិច្ចដំណើរការនីតិវិធីភ្លាម ចុះថ្ងៃទី ១ ខែ សីហា ឆ្នាំ ២០១៣ ឯកសារ E275/2/1/1។

*នៃបញ្ហាទាំងនេះ និងសក្តានុពលក្នុងការកែប្រែកាលកំណត់ ដែលត្រូវបានប្រកាសជាសាធារណៈរួចទៅហើយ នៅក្នុងកិច្ចដំណើរការនីតិវិធីនៃសំណុំរឿង ០០២/០១"*[3]។

៦. វាជារឿងគួរឲ្យភ្ញាក់ផ្អើលណាស់ ក្នុងការកត់សម្គាល់ឃើញថា អង្គជំនុំជម្រះទើបតែយល់នៅពេលនេះថា បញ្ហាទាំងនេះមានសារៈសំខាន់ ខណៈដែលកាលកំណត់បានចាប់ផ្ដើមគិតរួចទៅហើយ។

៧. ជាក់ស្តែង តាំងពីថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ២០១៣ មេធាវីការពារក្តីលោក ខៀវ សំផន បានស្នើសុំឲ្យរៀបចំកិច្ចប្រជុំរៀបចំសវនាការ ដើម្បីពិភាក្សាអំពីការរៀបចំសម្រាប់ការបញ្ចប់ការជំនុំជម្រះក្តី និងជាអាទិ៍ អំពីពេលវេលាពាក់ព័ន្ធនឹងសារណា និងសេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលក្នុងសំណុំរឿង ០០២/០១[4]។

៨. ទាំងមុន ក្នុង និងក្រោយកិច្ចប្រជុំសវនាការ នៅថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៣ មេធាវីការពារក្តីលោក ខៀវ សំផន បានលើកឡើងពីភាពចាំបាច់ក្នុងការកំណត់ជាស្ថាពរនូវវិសាលភាពនៃភ័ស្តុតាងដែលត្រូវទទួលយកក្នុងការជំនុំជម្រះក្តី (ត្រូវពិភាក្សាដេញដោលទាំងស្រុងតែម្តង) មុនពេលចាប់ផ្តើមគិតរយៈពេលតាក់តែងសារណាបញ្ចប់ការពិភាក្សាដេញដោល[5]។

---

[3] ការឆ្លើយឆ្លងគ្នាតាមអ៊ីមែល ដែលមានចំណងជើងថា *"អំពីសេចក្តីសម្រេចលើកំណត់ហេតុស្តាប់ចម្លើយសាក្សី"* រវាងលោក Kenneth ROBERTS មេធាវីការពារក្តីលោក នួន ជា និងមេធាវីការពារក្តីលោក ខៀវ សំផន ពីថ្ងៃទី ០៥ ដល់ថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០១៣ សូមមើលឧបសម្ព័ន្ធ។

[4] សំណើសុំឲ្យមានកិច្ចប្រជុំរៀបចំសវនាការ ដើម្បីកំណត់ប្រក្រតិទិនច្បាស់លាស់មួយ សម្រាប់ដំណាក់កាលសវនាការដែលនៅសេសសល់ ក្នុងសំណុំរឿង ០០២/០១ ចុះថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ២០១៣ ឯកសារ E284/1។

[5] កំណត់សម្គាល់របស់ក្រុមមេធាវីការពារក្តីលោក ខៀវ សំផន ដើម្បីកិច្ចប្រជុំរៀបចំសវនាការ នាថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៣ ឯកសារ E288/2 កថាខណ្ឌ ១១-៣០, ប្រតិចារឹកសវនាការ ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៣ ឯកសារ E1/207.1 ទំព័រ ២៨ បន្ទាត់ទី ១ ដល់ទំព័រ ៣០ បន្ទាត់ទី ៤, ប្រតិចារឹកសវនាការ ថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០១៣ ឯកសារ E1/227.1 ទំព័រ ៣៩ បន្ទាត់ទី ២៤ ដល់ទំព័រ ៤០ បន្ទាត់ទី ២៣, សូមមើលផងដែរ៖ សំណើបន្ទាន់របស់មេធាវីការពារក្តីលោក ខៀវ សំផន សុំឲ្យបញ្ឈប់កិច្ចដំណើរការនីតិវិធីភ្លាម ចុះថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០១៣ ឯកសារ E275/2/1/1 កថាខណ្ឌ ៧៣-៧៧ និងកថាខណ្ឌ ៨៩-៩១។

៩. នៅពេលលើកឡើងបញ្ហានេះម្តងៗ មេធាវីការពារក្តីមិនត្រឹមតែស្នើសុំឱ្យគិតកាលកំណត់ចាប់ពីពេលភាគីទទួលបានសេចក្តីសម្រេចទាំងអស់លើភាពអាចទទួលយកបាននៃភស្តុតាង ប៉ុណ្ណោះទេ ថែមទាំងស្នើសុំឱ្យអង្គជំនុំជម្រះផ្តល់បញ្ជីបច្ចុប្បន្នភាពនៃឯកសារដែលទទួលបានលេខសម្គាល់ E3 (ដែលអង្គជំនុំជម្រះអាចនឹងយកជាមូលដ្ឋានក្នុងការធ្វើសេចក្តីសម្រេច) ទៀតផង។ រៀងរាល់លើក មេធាវីការពារក្តីតែងតែពន្យល់អំពីសារៈសំខាន់នៃបញ្ហាទាំងនេះ សម្រាប់ការត្រៀមរៀបចំសារណាបញ្ចប់ការពិភាក្សាដេញដោល។

១០. ត្រង់ចំណុចនេះ យើងខ្ញុំសូមគូសបញ្ជាក់ថា នៅថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០១៣ ដោយប្រឈមមុខនឹងការលំបាកដូចគ្នា ភាគីទាំងអស់បានប្រកាន់គោលជំហរដូចគ្នា[6]។

១១. មេធាវីការពារក្តីលោក ខៀវ សំផន សូមបញ្ជាក់ថា សេចក្តីសម្រេចស្តីពីភាពអាចទទួលយកបាននៃកំណត់ហេតុស្តាប់ចម្លើយ ដែលមេធាវីការពារក្តីលោក នួន ជា បានលើកឡើង មិនមែនជាសេចក្តីសម្រេចតែមួយដែលមិនទាន់បានចេញរហូតមកដល់នឹងថ្ងៃនេះនោះទេ ខណៈដែលកាលកំណត់បានចាប់ផ្តើមគិតរួចទៅហើយ។ ឯកសាជិត ៨០០ ផ្សេងទៀត កំពុង "រង់ចាំការសម្រេចទទួលយក"[7]។ សំណើផ្សេងទៀតពាក់ព័ន្ធនឹងឯកសារភស្តុតាង ក៏មិនទាន់បានសម្រេចនៅឡើយដែរ[8]។

១២. មេធាវីការពារក្តីលោក ខៀវ សំផន យល់ឃើញថា ខ្លួនបានបង្ហាញទឡ្ហីករណ៍ និងសំណើគ្រប់គ្រាន់រួចហើយ និងមិនចង់លើកលម្អិតម្តងទៀតនោះទេ។ សូមអង្គជំនុំជម្រះពិនិត្យមើលសារណាមុនៗ

---

[6] ប្រតិចារឹកសវនាការ ថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០១៣ ឯកសារ E1/227.1 ទំព័រ ៣៦ បន្ទាត់ទី ៥-២០ (សហព្រះរាជអាជ្ញា) ទំព័រ ៣៧ បន្ទាត់ទី ៦-៩ (សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី) ទំព័រ ៣៧ បន្ទាត់ទី ១៦-១៨ និងទំព័រ ៣៨ បន្ទាត់ទី ៧-៩ (មេធាវីការពារក្តីលោក នួន ជា)។

[7] ប្រតិចារឹកសវនាការ ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៣ ឯកសារ E1/207.1 ទំព័រ ១៩ បន្ទាត់ទី ១៤ ដល់ទំព័រ ២០ បន្ទាត់ទី ៥។

[8] សំណើលើកទី ២ សុំដាក់បញ្ចូលអត្ថបទដកស្រង់ចេញពីសៀវភៅ លោក Marcel LEMONDE ទៅក្នុងកិច្ចពិភាក្សាដេញដោល ចុះថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ២០១៣ ឯកសារ E280/2, សំណើដោយផ្ទាល់មាត់របស់សហព្រះរាជអាជ្ញា សុំដាក់ឯកសារថ្មីមួយ ប្រតិចារឹកសវនាការ ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១៣ ឯកសារ E1/211.1 ទំព័រ ៥៧ បន្ទាត់ទី ២៤ ដល់ទំព័រ ៥៨ បន្ទាត់ទី ១០, សំណើរបស់មេធាវីការពារក្តីលោក ខៀវ សំផន សុំឱ្យពិនិត្យមើលឡើងវិញនូវការបកប្រែឯកសារពាក់ព័ន្ធនឹង "៨៧០" ដែលបានដាក់ចូលក្នុងសំណុំរឿង ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១៣ ឯកសារ E296។

និងអន្តរាគមន៍ដោយផ្ទាល់មាត់របស់យើងខ្ញុំលើបញ្ហាទាំងនេះ។ មេធាវីការពារក្តីលោក ខៀវ សំផន សូមបញ្ជាក់ថា យើងខ្ញុំគាំទ្រចំពោះទឡ្ហីករណ៍ទាំងអស់របស់មេធាវីការពារក្តីលោក នួន ជា នៅក្នុងសំណើ ក្រោមចំណងជើងថា *"សំណើសុំបំភ្លឺអំពីសេចក្តីសម្រេចលើភាពអាចទទួលយកបាននៃកំណត់ហេតុស្តាប់ចម្លើយសាក្សី ពាក្យបណ្តឹង និងប្រតិចារឹក និងសំណើសុំពន្យារកាលកំណត់ដាក់សារណាបញ្ចប់ការពិភាក្សាដេញដោល"*។

## អាស្រ័យហេតុនេះ

១៣. មេធាវីការពារក្តីលោក ខៀវ សំផន ស្នើសុំអង្គជំនុំជម្រះសាលាដំបូងមេត្តា៖

- កត់សម្គាល់ថា មេធាវីការពារក្តីលោក ខៀវ សំផន គាំទ្រទាំងស្រុងចំពោះទឡ្ហីករណ៍របស់មេធាវីការពារក្តីលោក នួន ជា។
- ចេញសេចក្តីសម្រេចមានសំអាងហេតុលើសំណើសុំទាំងអស់ពាក់ព័ន្ធនឹងឯកសារ។
- ផ្តល់បញ្ជីច្បាស់លាស់ និងជាស្ថាពរនៃឯកសារ ដែលទទួលបានលេខសម្គាល់ E3។
- គិតកាលកំណត់ដាក់សារណាបញ្ចប់ការពិភាក្សាដេញដោល ចាប់ពីពេលយើងខ្ញុំទទួលបានបញ្ជីឯកសារនេះ។

| | | | |
|---|---|---|---|
| | មេធាវី គង់ សំអុន<br><br>មេធាវី Anta GUISSÉ<br><br>មេធាវី Arthur VERCKEN | ទីក្រុងភ្នំពេញ<br><br>ទីក្រុងប៉ារីស<br><br>ទីក្រុងប៉ារីស | |